ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំស្តីពីបញ្ហាកសិផលពោត

**រាជធានីភ្នំពេញ៖** នៅរសៀលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ក្រសួងពាណិជ្ជកម្ម បានបើកកិច្ចប្រជុំស្តីពីបញ្ហាកសិផលពោត ក្រោមអធិបតីភាព **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងមានការចូលរួមពីមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទ តំណាងរោងចក្រចំណីសត្វ CP ម្ចាស់សៃឡូ (អ្នកទិញ-លក់បន្ត) និងសមាគមកសិករក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ប្រមាណ ៥០រូប។

កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងស្វែងរកដំណោះស្រាយសមស្រប សំដៅឆ្លើយតបនឹងការតវ៉ារបស់ប្រជាពលរដ្ឋ ជុំវិញការធ្លាក់ចុះនៃតម្លៃពោតក្រហមពី ៤៤០រៀល មកត្រឹម ៣៦០រៀល នៅក្នុងស្រុកកំរៀង និងស្រុកភ្នំព្រឹក នៃខេត្តបាត់ដំបង។

អង្គប្រជុំបានធ្វើការពិភាក្សាយ៉ាងផុសផុល ហើយបានរកឃើញនូវមូលហេតុសំខាន់ៗ ដែលនាំឲ្យតម្លៃពោតក្រហមធ្លាក់ចុះ មានដូចជា៖

(១). **អាកាសធាតុ៖** ឆ្នាំនេះមានភ្លៀងធ្លាក់ច្រើន ធ្វើឲ្យកសិករជួបការលំបាក ក្នុងការហាល និងសម្ងួតទិន្នផលពោត។

(២). **ប្រាក់កម្ចី៖** កសិករភាគច្រើន បានធ្វើការកាច់ពោតមុនពេលកំណត់ ដើម្បីលក់យកប្រាក់បង្វិលសងធនាគារ។

(៣). **ហេដ្ឋារចនាសម្ព័ន្ធ៖** កង្វះខាតឡសម្ងួត ដើម្បីហាលទិន្នផលពោត និងឃ្លាំងស្តុក ដើម្បីរក្សាទុករយៈពេលយូរ។

(៤). **តម្រៃក្រៅផ្លូវការ៖** ម្ចាស់សៃឡូដែលទិញពោត ពីកសិករត្រូវការបង់ចំណាយទៅលើសេវាមួយចំនួន ជូនមន្ត្រីពាក់ព័ន្ធនៅតាមមាត់ច្រកព្រំដែន។

(៥). **លើសបរិមាណ៖** នៅក្នុងប្រទេសថៃ គឺជារដូវប្រមូលទិន្នផលពោត ដែលធ្វើឲ្យឡសម្ងួតភាគច្រើនពេញប្រៀបដោយកសិផលពោត ដូច្នេះពាណិជ្ជករថៃ មិនអាចទទួលទិញកសិផលពោតខ្មែរច្រើនឡើយ។

ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ អង្គប្រជុំបានឯកភាពដាក់ចេញនូវវិធានការរយៈពេលខ្លី ដើម្បីលើកស្ទួយតម្លៃពោតក្រហម ជូនប្រជាកសិករ និងម្ចាស់សៃឡូដូចតទៅ៖

- ភ្នាក់ងារគយ និងកាំកុងត្រូល នឹងបញ្ឈប់ការយកកម្រៃលើការនាំចេញកសិផលពោត ចាប់ពីថ្ងៃនេះតទៅ។
- ក្រសួងពាណិជ្ជកម្ម នឹងចងក្រងរបាយការណ៍ ដើម្បីស្នើសុំទៅប្រមុខរាជរដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធ ធ្វើការកាត់បន្ថយការបង់ចំណាយក្រៅផ្លូវការឲ្យបាន ១០០%។
- ធនាគារអភិវឌ្ឍន៍ជនបទ នឹងបើកចំហរ ហើយត្រៀមខ្លួនជានិច្ច ដើម្បីធ្វើការជាមួយម្ចាស់សៃឡូ ដែលត្រូវការខ្ចីប្រាក់ដើម្បីទិញកសិផលពោត ឬ ធ្វើឡសម្ងួត និងពង្រីកឃ្លាំងស្តុកកសិផលជាដើម។ បច្ចុប្បន្ន ធនាគារមាន

គោលការណ៍ប្រើប្រាស់ឥណទានរបស់ខ្លួន ដែលមានទឹកប្រាក់សរុប ២៧លានដុល្លារអាមេរិក ជាមួយអត្រាការប្រាក់ពីចន្លោះ ៥% ទៅ ៧% ក្នុងមួយឆ្នាំ សម្រាប់ផ្តល់ជូនវិស័យឯកជន ជាមួយលក្ខខណ្ឌងាយៗ។

- ក្រុមហ៊ុនផលិតចំណីសត្វ CP នឹងប្រមូលទិញកសិផលពោត ទៅតាមស្តង់ដាឲ្យបានល្អប្រសើរជាងមុន។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសិក្សាបន្ថែមលើលទ្ធភាពបន្ធូរបន្ថយពន្ធ លើប្រាក់ចំណេញ សម្រាប់ទំនិញប្រភេទកសិផល។
- អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ និងនាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម នឹងធ្វើការសិក្សាបន្ថែមលើការអនុវត្តយន្តការកិច្ចសន្យាកសិកម្ម (Contract Farming) រវាងក្រុមហ៊ុនផលិតចំណីសត្វ និងកសិករដាំពោត ដើម្បីធានាបានស្ថេរភាពតម្លៃទីផ្សារក្នុងស្រុក និងការផ្គត់ផ្គង់។៖

អង្គប្រជុំ បានធ្វើការបញ្ចប់នៅក្រោមបរិយាកាសសប្បាយរីករាយ ដែលមានការឯកភាព និងសាទរពីគ្រប់ភាគីចូលរួមចំពោះដំណោះស្រាយដែលបានលើកឡើងនៅក្នុងអង្គប្រជុំ។៖

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម